**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២៦. អនក្រ.បក

លេខ...៥០៧០...

ថ្ងៃ...០៥/១២/១៣

# អនុក្រឹត្យ

## ស្តីពី

## ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងនិងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិកសិកម្ម ដើម្បីទទួលបាននូវព័ត៌មានគ្រប់ផ្នែកក្នុងវិស័យកសិកម្មនិងធ្វើជាទិន្នន័យមូលដ្ឋានសម្រាប់អ្នកប្រើប្រាស់និងអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងនានា ដើម្បីជំរុញកិច្ចអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់ការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្មទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ការកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់អង្គភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្ម ក្រោមការគ្រប់គ្រងតែមួយ រួមមានរាល់ដំណាំគ្រប់ប្រភេទ បសុសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រីចិញ្ចឹមគ្រប់ប្រភេទ វារីវប្បកម្ម និងរាល់ដីធ្លីបានប្រើប្រាស់ទាំងមូលឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពីកម្មសិទ្ធិ ឬទម្រង់ផ្លូវច្បាប់។ ការកាន់កាប់ផលិតកម្មកសិកម្មអាចមានក្បាលដីមួយឬច្រើន ដែលស្ថិតនៅក្នុងតំបន់មួយឬច្រើនដោយឡែកពីគ្នាក្នុងខេត្តតែមួយ ឬក្នុងតំបន់ត្រួតត្រាមួយឬច្រើន ឬតំបន់រដ្ឋបាលនៃប្រទេស ដែលមានក្បាលដីប្រើមធ្យោបាយផលិតកម្មតែមួយ ដូចជាពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬសត្វអូសទាញ។
- **ជំរឿនកសិកម្ម** សំដៅដល់ការប្រមូលទិន្នន័យអំពីការប្រើប្រាស់ដីធ្លី ការដាំដុះដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វគ្រប់ប្រភេទ ជលផល និងវារីវប្បកម្មក្នុងរយៈពេលយោងជាក់លាក់។
- **អ្នកកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់គ្រួសារ ឬនីតិបុគ្គលដែលគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ លើការប្រតិបត្តិនៃការកាន់កាប់ផលិតកម្មកសិកម្ម។

## ជំពូកទី២

## កាលបរិច្ឆេទ

**មាត្រា ៥.-**

កាលបរិច្ឆេទជំរឿនកសិកម្ម ឆ្នាំ២០១៣ កំណត់នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣។

# ជំពូកទី៣
# យន្តការនិងនីតិវិធី

**មាត្រា ៦.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងផែនការ ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ១រូប | សមាជិក |
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ | លេខាធិការ ។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនកសិកម្ម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៧.-**

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ ត្រូវបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម គណៈកម្មការឃោសនាជំរឿនកសិកម្ម និងគណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត ដែលកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិជំរឿនកសិកម្ម។

**មាត្រា ៨.-**

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ មានភារកិច្ច៖

- ណែនាំ និងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនកសិកម្ម
- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម និងគណៈកម្មការឃោសនាជំរឿនកសិកម្មមានទីស្នាក់ការនៅក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការជំរឿនកសិកម្ម
- រៀបចំនិងបង្កើតគណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត
- ចាត់តាំងមន្ត្រីឲ្យចូលរួមជំរឿនកសិកម្ម តាមការស្នើសុំរបស់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
- ប្រជុំការងារយ៉ាងតិច០៦(ប្រាំមួយ)ខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន
- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនកសិកម្ម។

**មាត្រា ៩.-**

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ មានទីតាំងនៅក្រសួងផែនការនិង[illegible]របស់ក្រសួងផែនការ។

គណៈកម្មការបច្ចេកទេសជំរឿនកសិកម្មនិងគណៈកម្មការឃោសនាជំរឿនកសិកម្ម មានសិទ្ធិប្រើត្រារបស់ក្រសួងផែនការ។

គណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត មានសិទ្ធិប្រើត្រារបស់រាជធានី ខេត្ត។

**មាត្រា ១០.-**

ប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មមានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងប្រជាជន ដើម្បីសហការជួយធ្វើកិច្ចការជំរឿនកសិកម្ម។

**មាត្រា ១១.-**

ជំរឿនកសិកម្ម ឆ្នាំ២០១៣ ត្រូវមានដំណាក់កាលដូចតទៅ៖

១- កិច្ចប្រតិបត្តិការដំបូងរបស់ការជំរឿនមាន៖

- ការរៀបចំផែនទី
- ការធ្វើអង្កេតនិងជំរឿនសាកល្បង។

២- ការធ្វើសម្ភាសការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្ម។

៣- កិច្ចប្រតិបត្តិការចុងក្រោយរបស់ការជំរឿនមាន៖

- ការធ្វើអង្កេតសម្រាប់វាយតម្លៃលើការជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀតក្នុងករណីចាំបាច់។

**មាត្រា ១២.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទទួលបន្ទុកការងារជំរឿនកសិកម្មនិងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរផែនការនិងមន្ទីរកសិកម្ម រាជធានី ខេត្ត ជួយរាល់ការងារក្នុងការជំរឿន។

**មាត្រា ១៣.-**

មន្ត្រីបំពេញការងារជំរឿន រួមមានអ្នកត្រួតពិនិត្យការសម្ភាស អ្នកសម្ភាសស្រង់យកព័ត៌មាន និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការធ្វើជំរឿន ត្រូវចាត់តាំងដោយគណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ តាមការស្នើសុំរបស់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ។ ការចាត់ចែងនេះអនុវត្តបានតែក្នុងអំឡុងពេលធ្វើជំរឿនតែប៉ុណ្ណោះ។

**មាត្រា ១៤.-**

អ្នកកាន់កាប់ផលិតកម្មកសិកម្ម ត្រូវសហការនិងអនុញ្ញាតឲ្យមន្ត្រីបំពេញការងារជំរឿនដែលបង្ហាញលិខិតបេសកកម្មផ្លូវការ បានចូលក្នុងទីតាំងនៃផលិតកម្មកសិកម្ម លំនៅឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការជំរឿន និងអនុញ្ញាតឲ្យមន្ត្រីទាំងនោះអាចលាបពណ៌ បិទអក្សរ បិទសញ្ញាឬលេខសម្គាល់នៅតាមកន្លែងចាំបាច់ សម្រាប់បម្រើដល់ការងារជំរឿនកសិកម្ម។

**មាត្រា ១៥.-**

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ អាចចាត់តាំងអ្នកគ្រប់គ្រងជំរឿនកសិកម្ម តាមទីកន្លែងដែលមានលក្ខណៈពិសេសដូចខាងក្រោម៖

ក- អ្នកគ្រប់គ្រងទីតាំងនៃផលិតកម្មកសិកម្មសាធារណៈនិងឯកជនដែលមានទ្រង់ទ្រាយធំ។

ខ- អ្នកគ្រប់គ្រងផលិតកម្មកសិកម្មផ្សេងទៀតដែលចាំបាច់។

**មាត្រា ១៦.-**

មន្ត្រីដែលគ្មានភារកិច្ចទទួលខុសត្រូវក្នុងការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យ[illegible] ឬសំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

## ជំពូកទី៤
## ធនធាន

**មាត្រា ១៧.-**

ជំរឿនកសិកម្ម ឆ្នាំ២០១៣ មានប្រភពធនធានដូចតទៅៈ

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា
- ប្រភពធនធានស្របច្បាប់ផ្សេងៗ

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៥ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល ៖**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

<u>លេខ ៤៥៥ ចល.កសក</u>

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក ៖
-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
« ដើម្បីជូនជ្រាប »
-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត
« ដើម្បីជ្រាបនិងមុខការ »

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៥ ឆ្នាំ ២០១២

ត.ល រដ្ឋមន្ត្រី

**អគ្គលេខាធិការ**